

Photo courtesy of WaterSHED.

**អត្ថបទសង្ខេបនៃការស្រាវជ្រាវ**

## ការសិក្សាស្រាវជ្រាវ ជាលក្ខណៈដៃគូ អំពីប្រព័ន្ធទឹក និងអនាម័យ ដែលមាននិរន្តរភាព

# ការវិភាគបណ្តាញ និង ការវាយតម្លៃប្រព័ន្ធ នៅក្នុងវិស័យអនាម័យជនបទ ប្រទេសកម្ពុជា

ខែមីនា ឆ្នាំ ២០១៨

## សេចក្តីណែនាំ

សេចក្តីសង្ខេបនៃការស្រាវជ្រាវនេះបង្ហាញអំពីលទ្ធផលដំបូង និងចំណេះដឹង ដែលបានរៀនសូត្រពីការសិក្សា អំពីទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ និងកត្តាជោគជ័យសំខាន់ៗ សម្រាប់បណ្តាញ អនាម័យជនបទនៅក្នុងប្រទេសកម្ពុជា។ យុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា សម្រាប់ការផ្គត់ផ្គង់ទឹក និងអនាម័យ ឆ្នាំ ២០១១-២០២៥ បានកំណត់ច្បាស់នូវចក្ខុវិស័យ៖ “ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទ ទទួលបានសេវាផ្គត់ផ្គង់ទឹក ដែលមានសុវត្ថិភាព និង អនាម័យប្រកបដោយនិរន្តភាព និងរស់នៅក្នុងបរិស្ថានប្រកបដោយអនាម័យមួយនៅឆ្នាំ២០២៥។” ប៉ុន្តែយ៉ាងណាមិញ អនុក្រុមអនាម័យជនបទនៅក្នុងប្រទេសកម្ពុជា ជួបប្រទះនឹងបញ្ហាប្រឈម ចំបងមួយចំនួនដើម្បីសម្រេចបាននូវចក្ខុវិស័យ។ អនុក្រុមនេះមានអ្នកពាក់ព័ន្ធជាច្រើនចូលរួម ហើយក្រុមផែនការយុទ្ធសាស្ត្រជាតិសង្កេតឃើញថា វាពុំទាន់មានការរៀបចំ និង ការប្រមូលផ្តុំ ដែលនេះបណ្តាលឲ្យនិរន្តរភាព នៃលទ្ធផលការចុះអន្តរាគមន៍ជាទូទៅមានកំរិតទាប។ កិច្ចខិតខំ ប្រឹងប្រែង នៃការសហការបច្ចុប្បន្ន មានការចូលរួមអំពីក្រុមសំខាន់ៗ ដូចជា រដ្ឋាភិបាល និងអង្គការ ក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ ដោយគ្មានការចូលរួមសំខាន់ពីសំណាក់ វិស័យឯកជន និង ក្រុមដទៃទៀត ដែលមានពីមុនមកនៅក្នុងវិស័យ។

ដើម្បីឆ្លើយតបទៅលើបញ្ហានេះ អង្គការវ៉តធើសេដកម្ពុជា ដោយមានការសហការជាមួយលីង (LINC) កំពុងសម្របសម្រួលយុទ្ធសាស្ត្របែបប្រព័ន្ធមួយ ដែលមានលក្ខណៈជាម្ចាស់ការ និង ដឹកនាំដោយថ្នាក់មូលដ្ឋានផ្ទាល់  ដែលវិធីសាស្ត្រនេះ គឺផ្សារភ្ជាប់អ្នកពាក់ព័ន្ធទាំងឡាយ នៅក្នុងវិស័យអនាម័យជនបទនៅថ្នាក់ជាតិ តាមរយៈការខិតខំប្រឹងប្រែងសហការគ្នាបែបរចនាសម្ព័ន្ធយ៉ាងម៉ត់ចត់មួយ។ ក្រុមការងារលីង (LINC) បានដឹកនាំការវិភាគ នៃការស្ទង់មតិ ដើម្បីស្វែងយល់ពីអ្នកពាក់ព័ន្ធ ដែលកំពុងធ្វើការនៅវិស័យអនាម័យជនបទ (យើងសំដៅដល់ក្រុម ដែលមិនមែនជា ផ្លូវការនេះ ថាជាបណ្តាញវិស័យអនាម័យជនបទ)។ គោលបំណង នៃការសិក្សានេះ គឺដើម្បីគាំទ្របណ្តាញអនាម័យជនបទក្នុងការបង្កើតការស្វែងយល់ ការពិភាក្សា និង សកម្មភាពបែបសហការ ដែលនឹងពន្លឿនដល់វឌ្ឍនភាពឆ្ពោះទៅចក្ខុវិស័យ។ ការវិភាគនេះសិក្សាអំពីទំនាក់ទំនងនៅក្នុងបណ្តាញវិស័យអនាម័យជនបទ និង ទំនាក់ទំនងរវាងគ្នា នៃកត្តាជោគជ័យ និង ឧបសគ្គផ្សេងៗ ដើម្បីសម្រេចបាននូវចក្ខុវិស័យ។

### យុទ្ធសាស្ត្រជាតិ និងគោលបំណង

**១. ការផ្គត់ផ្គង់ទឹក៖**
៥០% នៃចំនួនប្រជាពលរដ្ឋនៅតាមជនបទ នឹងទទួលបានសេវាផ្គត់ផ្គង់ទឹក និងរស់នៅក្នុងបរិស្ថានប្រកបដោយអនាម័យ ឆ្នាំ ២០១៥ និង ១០០% នៅឆ្នាំ២០២៥។

**២. អនាម័យ៖**
៣០% នៃចំនួនប្រជាពលរដ្ឋនៅជនបទ នឹងទទួលបានសេវាអនាម័យ និងរស់នៅក្នុងបរិស្ថានប្រកបដោយអនាម័យ ឆ្នាំ ២០១៥ និង ១០០% នៅឆ្នាំ ២០២៥។

**៣. អនាម័យខ្លួនប្រាណ៖**
៣០%នៃចំនួនប្រជាពលរដ្ឋនៅតាមជនបទ នឹងផ្លាស់ប្តូរឥរិយាបទអនុវត្តអនាម័យ ដែលមានសុវត្ថិភាពនៅឆ្នាំ ២០១៥ និង ១០០% នៅឆ្នាំ ២០២៥។

**៤. បរិស្ថានដែលមានលក្ខណៈជំរុញ៖**
ត្រឹមឆ្នាំ ២០១៥ ការរៀបចំស្ថាប័ន ឯកសារផ្លូវការ និងធនធានមនុស្ស នឹងមានជារូបរាង ហើយអាចបង្កើនសេវាកម្មយ៉ាងឆាប់រហ័ស និងធ្វើឲ្យសេវាកម្មទាំងនោះនៅតែបន្តមាន។

**៥. ហិរញ្ញវត្ថុ៖**
ថវិកាសម្រាប់ធនធាន និងការចំណាយ នឹងមានប្រើប្រាស់

USAID FROM THE AMERICAN PEOPLE

SUSTAINABLE WASH SYSTEMS A LEARNING PARTNERSHIP

## វិធីសាស្ត្រ

អង្គការវ៉តធើសេដ និង ស្ថាប័នលីង (LINC) បានបង្កើតការវិភាគ ដើម្បីវាយតម្លៃបណ្តាញអនាម័យជនបទ និង ភាពស្របគ្នារបស់វិស័យ ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់រដ្ឋាភិបាលនៅឆ្នាំ ២០២៥។ បន្ទាប់ពីសិក្ខាសាលានៅខែមិថុនា ឆ្នាំ២០១៧ ដែលមានការចូលរួមពីបណ្តាអ្នកពាក់ព័ន្ធជាច្រើន ដើម្បីណែនាំការវិភាគបណ្តាញ និងប្រព័ន្ធផែនទី ក្រុមការងារបានបង្កើតនូវ ឧបករណ៍ស្ទង់មតិ និងបញ្ជីឈ្មោះ ដែលបានកំណត់ទុកមុននៃអង្គការ និងស្ថាប័នប្រមាណជាង ១០០។ បញ្ជីនេះ គឺតំណាងឲ្យវត្តមានស្ថាប័ន ឬ អង្គការសរុបទាំងអស់ ដែលត្រូវបានចាត់ទុកថាមានលក្ខខ័ណ្ឌគ្រប់គ្រាន់ សម្រាប់ការវិភាគបណ្តាញ (1)។ តំណាងអង្គការ ៩៩ ត្រូវបានសម្ភាសន៍ ចាប់ តាំងពីខែ មិថុនា ដល់ខែ កញ្ញា ឆ្នាំ ២០១៧ រួមមានបុគ្គលិករាជរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នសិក្សា និង អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ នៅក្នុងចំណោមស្ថាប័ន ដែលបានសម្ភាសន៍ មានស្ថាប័ន ចំនួន ៨៨ ដែលចាត់ ចូលនៅក្នុងបណ្តាញ ដោយផ្អែកលើលក្ខខ័ណ្ឌជាសមាជិក និង ទំនាក់ទំនងជាមួយនឹងសមាជិកបណ្តាញដ៏ទៃទៀត។

កិច្ចសម្ភាសន៍មាន ៣ ផ្នែក៖

១. ជាសំណួរបិទ ដើម្បីស្វែងយល់អំពីគុណលក្ខណៈ នៃស្ថាប័នរបស់អ្នកឆ្លើយសំណួរ

២. សំណួរអំពីទំនាក់ទំនងក្នុង ៦ ខែចុងក្រោយរបស់អង្គការ ឬស្ថាប័នចូលរួមជាមួយដៃគូរដទៃទៀតនៅក្នុងបញ្ជី

៣. សំណួរបើកចំនួន ៥ អំពីកត្តាជោគជ័យសំខាន់ៗ និងឧបសគ្គក្នុងការសម្រេចបាននូវចក្ខុវិស័យ។

ការវិភាគទិន្នន័យមាន ៣ ផ្នែកពាក់ព័ន្ធគ្នា៖

- **ការវិភាគបណ្តាញ៖** ទំនាក់ទំនងនៃតួអង្គនីមួយៗ ត្រូវបានសិក្សា ដើម្បីកំណត់លំនាំ នៃការផ្សារភ្ជាប់គ្នាទៅវិញទៅមក នៅក្នុងបណ្តាញដៃគូរ និងក្រុមដែលមានឥទ្ធិពល និងទំនាក់ទំនងខ្លាំង និងចន្លោះខ្វះខាត ឬឱកាសនៅក្នុងបណ្តាញ។
- **ការវិភាគកត្តា៖** ចម្លើយរបស់អ្នកចូលរួមទៅលើសំណួរបើក អំពីចក្ខុវិស័យរបស់វិស័យ និង ការយល់ឃើញទៅលើកត្តាជោគជ័យ និង ឧបសគ្គផ្សេងៗត្រូវបានធ្វើជាកូតបែងចែកជាក្រុម និងធ្វើការវិភាគ ដើម្បីស្វែរកគំនិតសំខាន់ៗ ដែលលេចចេញ។
- **ផែនទីប្រព័ន្ធ៖** ត្រូវបានធ្វើឡើង ដោយផ្អែកលើភាពពឹងពាក់គ្នាផ្សេងៗ ដែលអ្នកចូលរួមបានបកស្រាយនៅពេលបទសម្ភាសន៍សំណួរបើក។ ផែនទីនេះ បង្ហាញអំពីការផ្សារភ្ជាប់ រវាងកត្តាជោគជ័យ និង ឧបសគ្គក្នុងការសម្រេចបាននូវចក្ខុវិស័យ។

(1) លក្ខណៈវិនិច្ឆ័យសមាជិកភាពបណ្តាញ RuSH: (ក) ការិយាល័យអចិន្ត្រៃយ៍នៅក្នុងរដ្ឋធានី, រាជធានីភ្នំពេញ និង (ខ) ការប្តេជ្ញាចិត្តចំពោះ RuSH ដូចដែល បានបង្ហាញយ៉ាងហោចណាស់មួយដូចខាងក្រោម: យុទ្ធសាស្ត្រឬបេសកកម្ម ដែលរួមបញ្ចូលទាំងការផ្តោតលើ RuSH មួយ; ឬ បីឬបុគ្គលិកបន្ថែម ដែលចំណាយពេល 50% ឬច្រើនជាងនេះលើបញ្ហា RuSH ។ ឬថវិកាប្រចាំឆ្នាំសម្រាប់សកម្មភាព RuSH ដែលមានតំលៃ 25.000 ដុល្លារឬច្រើនជាងនេះ។

បន្ទាប់ពីការវិភាគលទ្ធផលបឋម ក្រុមការងារលីង (LINC) និង អង្គការវ៉តធើសេដ បានធ្វើសិក្ខាសាលាពិគ្រោះយោបល់មួយ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធ ប្រមាណជាង ១០០ នាក់ នៅក្នុងវិស័យអនាម័យជនបទ ដើម្បីបង្ហាញ និងឲ្យអ្នកចូលរួមទាំងអស់ពិភាក្សាទៅលើលទ្ធផល។ សិក្ខាសាលានេះ ក៏ដើម្បីប្រមូលនូវមតិយោបល់ដំបូង ដើម្បីបញ្ចូលទៅក្នុងការវិភាគ។



អ្នកចូលរួមជាង 100 នាក់មកពីវិស័យ RuSH បានចូលរួមក្នុងពិធីសិក្ខាសាលានេះ ដើម្បីពិភាក្សាអំពីការរកឃើញនៃបណ្តាញរៀបចំការវិភាគ។ រូបថតដោយ WaterSHED។

## លទ្ធផល

ប្រព័ន្ធនៃការវិភាគលើកដំបូង បានរកឃើញចំណុចគួរឲ្យចាប់អារម្មណ៍ដែលជាសក្តានុពល ដើម្បីធ្វើឲ្យប្រសើរឡើងក្នុងការឈានទៅរកការជោគជ័យ នៃចក្ខុវិស័យ។ ខាងក្រោមនេះជាសំណាកថលទ្ធផលគន្លឹះ ដែលឆ្លុះបញ្ជាំងចម្លើយអ្នកពាក់ព័ន្ធ និង បង្ហាញអំពីគំនិតសំខាន់ៗ ផ្សេងៗ ដែលលេចចេញពីការវិភាគ។ សំរាប់ព័ត៌មានលម្អិត សូមពិនិត្យរបាយការណ៍ពេញ។

### ក. ភាពខុសគ្នា នៃការភ្ជាប់បណ្តាញទៅវិញទៅមក ដោយផ្អែកទៅលើយេនឌ័រ និង ភាសា

ការវិភាគបណ្តាញបានកំណត់ច្បាស់ នៃភាពខុសគ្នានៅក្នុងការវាស់វែងមួយចំនួន នៃការតភ្ជាប់ ដែលអាស្រ័យទៅលើយេនឌ័រ នៃប្រធានស្ថាប័ន និង ភាសាដែលបានប្រើពេលសម្ភាសន៍ (ភាសាខ្មែរ ឬ ភាសាអង់គ្លេស)។

បើតាមយេនឌ័រ អង្គការ ដែលដឹកនាំដោយស្ត្រី មាន ទំនាក់ទំនងតិចជាង ហើយមិនមែនជាចំណុចកណ្តាលនៅក្នុងបណ្តាញបើប្រៀបធៀបទៅនឹងអង្គការដែលដឹកនាំដោយបុរស។ ជាមធ្យមស្ថាប័នទាំងនោះ បានឆ្លើយថាពួកគេមានទំនាក់ទំនង តិចជាង ៦០% នៃទំនាក់ទំនង ដែលអង្គការដែលដឹកនាំដោយបុរសមាន។ បណ្តាញអង្គការដែលមានស្ត្រីជាអ្នកដឹកនាំសុទ្ធ(2) គឺមាន ទំនាក់ទំនងខ្លាំងបានតែពាក់កណ្តាល នៃបណ្តាញអង្គការ ដែលមាន បុរសជាអ្នកដឹកនាំសុទ្ធ។

(2) ផ្អែកលើដង់ស៊ីតេនៃបណ្តាញនីមួយៗ។ ដង់ស៊ីតេ គឺជាសមាមាត្រ នៃការតភ្ជាប់ពិតប្រាកដទៅការតភ្ជាប់ ដែលអាចធ្វើបានទាំងអស់នៅក្នុងបណ្តាញ។

ជាមធ្យមអង្គការ ដែលមានស្ត្រីជាអ្នកដឹកនាំមានមជ្ឈករ (គំលាត ទំនាក់ទំនង ពីស្ថាប័នមួយទៅស្ថាប័នមួយ) តិចជាងពាក់កណ្តាល នៃអង្គការដែលមានបុរសជាអ្នកដឹកនាំ មានន័យថាអង្គការ ដែលស្ត្រីអ្នកដឹកនាំ មានកំរិតទាបជាស្ពានក្នុងការផ្សាភ្ជាប់រវាងគូរអង្គពីរផ្សេងគ្នា។

លទ្ធផល រកឃើញជុំវិញការប្រើប្រាស់ភាសាបានបង្ហាញថា បើទោះជាអង្គការដែលបាន សម្ភាសន៍ជាភាសាអង់គ្លេស គ្រាន់តែជាមួយផ្នែកតូច នៃបណ្តាញទាំងមូល តែអង្គការទាំងនោះមានទំនាក់ទំនងខ្ពស់រវាងគ្នា និងគ្នាជាមួយបណ្តាញទាំងមូល។ អង្គការដែលបាន សម្ភាសន៍ជាភាសាអង់គ្លេស ស្ទើរតែមានទំនាក់ទំនងរវាងគ្នា និងបណ្តាញទាំងមូល បួនដងខ្ពស់ជាងអង្គការ ដែលសម្ភាសន៍ជាភាសាខ្មែរ ហើយជាមធ្យមអង្គការទាំងនោះមានទំនាក់ទំនងជាង៨០% លើសអង្គការ ដែលបានសម្ភាសន៍ជាភាសាខ្មែរ។ អង្គការទាំងអស់នោះ ក៏នៅក្នុងចំណោមអង្គការ ដែលនៅចំកណ្តាលបណ្តាលនៅក្នុងបណ្តាញ ហើយក៏នៅក្នុងចំណោមអង្គការដែលសមាជិកដទៃទៀតក្នុងបណ្តាញចង់មានទំនាក់ទំនងជាមួយបំផុត។

ដោយសារតែយេនឌ័រ ដែលជាអ្នកដឹកនាំអង្គការ និងភាសា គ្រាន់តែជាតំណាងនៃការសម្ភាសន៍ សំរាប់កំណត់បញ្ហាយេនឌ័ និងភាសា នៅក្នុងបណ្តាញ លទ្ធផលនេះបង្ហាញ ថាបណ្តាញអនាម័យជនបទ គួរតែធ្វើការសិក្សាបន្ថែម ដើម្បីស្វែងយល់អំពីកត្តាគោលសំខាន់ នៃវិសមភាពទាំងនេះនៅក្នុងបណ្តាញ។ បណ្តាញអនាម័យជនបទ បានចាប់ផ្តើមឆ្លើយតបទៅនឹងភាពលំអៀង ដែលមានសក្តានុពលទាំងនេះ ជាមួយនឹងជំហ៊ានការលើកកម្ពស់ស្ត្រី នៅក្នុងបណ្តាញទឹក និងអនាម័យ និងការជំរុញច្រើនជាងមុនលើការប្រើប្រាស់ភាសា ២ ក្នុងការទំនាក់ទំនង (សូមមើលបន្ថែមពីការរៀនសូត្រនៅផ្នែកខាងក្រោម)។

### ខ. ក្រសួងអភិវឌ្ឍន៍ជនបទ គឺនៅចំណុចសំខាន់ ដែលអាចដឹកនាំការសម្របសម្រួល និងការសហការ ដែលមានភាពប្រសើរ

ការវិភាគបណ្តាញនេះ បង្ហាញថាក្រសួងអភិវឌ្ឍន៍ជនបទជាដៃគូ ដែលនៅចំកណ្តាលបំផុតនៃបណ្តាញទាំងមូល មានន័យថាស្ថាប័ននេះ គឺដើរតួនាទីយ៉ាងសំខាន់ នៅក្នុងបណ្តាញដើម្បីធ្វើអោយ ប្រសើរឡើងនូវវិស័យអនាម័យជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទ ជាញឹកញាប់ជាស្ពានផ្សាភ្ជាប់រវាងដៃគូរដទៃទៀត ហើយមានទំនាក់ទំនងដៃគូរហូតដល់ ២ ដងលើសដៃគូ ដែលមានទំនងទំនងខ្ពស់បន្ទាប់ទៀត (សូមមើលរូបភាព ទី១ សំរាប់បណ្តាញក្រសួងនៅផែនទី)។ ការវិភាគបណ្តាញបង្ហាញថា “ការចូលរួមរបស់រាជរដ្ឋាភិបាល” ត្រូវបានលើកឡើងថា ជាកត្តាជោគជ័យទី២ នូវការសំរេចចក្ខុវិស័យ។

ការវិភាគ ក៏បានកត់សម្គាល់នូវការកិច្ចខិតខំប្រឹងប្រែងមួយចំនួន ដែលជាន់គ្នា។ ជាមធ្យមអង្គការនីមួយៗអនុវត្ត 5.6 នៃចំនួនសរុប ១៣ ប្រភេទសកម្មភាព ដែលបានសំភាសន៍ អង្គការខ្លះទៀត អនុវត្តបាន ១១ ប្រភេទសកម្មភាព និង សរុប ២៦% នៃបណ្តាញ (២៣អង្គការ) កំពុងអនុវត្ត៨ ឬច្រើនជាងនេះ នៃប្រភេទសកម្មភាព។ លើសពីនេះទៀត ការវិភាគកត្តាបង្ហាញថា យន្តការការសហការ ត្រូវបានលើកឡើងច្រើនជាងគេថា ជាកត្តាជោគជ័យ។ តែទោះជាការមានលើកឡើងយ៉ាងនេះក្តី នៅពេលដែលសំណួរចោទសួរពីចំនុចអ្វី ដែលត្រូវប្រឹងប្រែង និងចំណាយពេលវេលាទៅលើ ការសហការ និងការសម្របសម្រួល បែរជាធ្លាក់លំដាប់ទៅលេខរៀងទី៦ វិញ ដែលស្ថាប័នផ្សេងបានលើកឡើង។

លទ្ធផលការសិក្សាទាំងនេះ បានបង្ហាញថាក្រសួងអភិវឌ្ឍន៍ជនបទ គួរតែប្រើប្រាស់សក្តានុពល ដែលជាចំណុចកណ្តាល និងការផ្សាភ្ជាប់ ដែលមានកម្រិតខ្ពស់របស់ក្រសួង ដើម្បីសម្របសម្រួល ធ្វើអោយប្រសើរឡើង និងពង្រឹងបន្ថែមទៅលើការសម្របសម្រួល និង ការសហការ។ ដើម្បីធ្វើការគាំទ្រទៅលើសកម្មភាពនេះ អ្នកពាក់ព័ន្ធក្នុងបណ្តាញអនាម័យជនបទដទៃទៀត គួរតែចូលរួមសកម្ម និង ធ្វើការសហការគ្នាអោយសកម្ម នៅក្នុងការបង្កើតយន្តការ សំរាប់ការសហការដែលមានលក្ខណៈបែបរចនាសម្ព័ន្ធ។




ផែនទី ទី១ នៃបណ្តាញអភិវឌ្ឍន៍ជនបទ នៃប្រទេសកម្ពុជា

### គ. អនុក្រុម ដែលមានស្រាប់ ទៅតាមប្រធានបទ នៅក្នុងបណ្តាញ ជាតំណាងគំរូដ៏រឹងមាំមួយ សម្រាប់ការសហការ

បច្ចុប្បន្នវិស័យមានអនុក្រុមទៅតាមប្រធានបទជាក់លាក់មួយចំនួន ដែលជួបប្រជុំគ្នាជាប្រចាំ។ សមាជិក ដែលនៅក្នុងអនុក្រុមមិនមែនជាលក្ខណៈផ្លូវការ ស្ថាប័ននីមួយៗខ្លួនឯងជាអ្នកសម្រេចចិត្ត ក្នុងការចូលរួម។ យោងតាមការវិភាគនៃបណ្តាញក្រុម ៣ ដែលសកម្មក្នុងការចូលរួម (ដោយផ្អែកទៅលើសម្រង់អវត្តមាន ដែលបានប្រមូលចងក្រងមុនពេលសិក្សា និងក្នុងកំឡុងពេល សិក្សា) បានបង្ហាញពីភាពខុសគ្នាគួរអោយចាប់អារម្មណ៍មួយចំនួនពីបណ្តាញទាំងមូល។ ការវិភាគបណ្តាញបានចង្អុលបង្ហាញអោយឃើញថា អនុក្រុម ដែលមានស្រាប់ គឺមានទំនាក់ទំនងជាមួយគ្នា ក្នុងបណ្តាញយ៉ាងខ្លាំង ហើយជាចំនុចកណ្តាលសំខាន់ នៃបណ្តាញទាំងមូល។ ការវិភាគកត្តាបានបង្ហាញថា អនុក្រុមទាំងនោះបានចាត់ទុកថា ការសហការសំខាន់ បើប្រៀបធៀបទៅនឹងបណ្តាញទាំងមូល។ ពួកគេប្រមាណ ៨០ ភាគរយ នៃស្ថាប័នទាំងមូលបានលើកឡើងខណៈ ដែលសមាជិក នៃបណ្តាញទាំងមូល ត្រឹមតែ ៥៨ ភាគរយប៉ុណ្ណោះ ដែលគិតថាការសហការសំខាន់។ ផ្ទុយទៅវិញ ខុសពីបណ្តាញទាំងមូល អនុក្រុមនៃវិស័យ នៅតែចាត់ថ្នាក់ការសហការជាអ្វី ដែលគួរចំណាយពេល និងការខិតខំប្រឹងប្រែង ទៅលើ ពេលដែលចោទសួរសំណួរនេះ។

សារៈសំខាន់សំរាប់ការគិតពិចារណា អនុក្រុម ដែលមានស្រាប់ជាយន្តការសក្តានុពលមួយ និងជាគំរូយ៉ាងច្បាស់ សម្រាប់បង្កើតការសម្របសម្រួលនិង ការសហការនៃបណ្តាញជា លក្ខណៈ: រចនាសម្ព័ន្ធ។

ការវិភាគនៃអនុក្រុមទាំងនេះ (សក្តានុពលនៃទំរង់ផ្សេងទៀត) គួរតែបញ្ចូលអោយមានការពិនិត្យ និងតាមដាន ក្នុងការវិភាគ នៅក្នុងរយៈពេល២ ឬ ៣ឆ្នាំ បន្ទាប់ដើម្បីវាយតម្លៃ ការផ្លាស់ប្តូររយៈ ពេល ដែលកន្លងផុតទៅ។

## បទពិសោធន៍នៃការរៀនសូត្រ

មេរៀន ដែលគួរអោយកត់សំគាល់មួយចំនួន នៅក្នុងដំណើរការ និងគុណតម្លៃនៃការវិភាគប្រព័ន្ធ បានប្រមូលពីការសិក្សា និង មតិយោបល់។ យើងសង្ឃឹមថាមេរៀនក៏ដូចជាបទពិសោធន៍នេះ មិនត្រឹមតែមានទំនាក់ទំនងនឹងការងារវិស័យអនាម័យជនបទនៅក្នុង ប្រទេសកម្ពុជាប៉ុណ្ណោះទេ តែវាជាទម្រង់ឬជាគំរូមួយ នៃការវិភាគ បណ្តាញ និងការវាយតំលៃប្រព័ន្ធដ៏ទៃទៀត។

### ការចូលរួម ពីអ្នកពាក់ព័ន្ធក្នុងការបកស្រាយ ស្វែងយល់ និង ដើរតួនាទី ក្នុងប្រព័ន្ធនៃការវិភាគ គឺមានភាពប្រឈម និងលំបាក

សិក្ខាសាលាពិគ្រោះយោបល់កាលពីខែធ្នូឆ្នាំ២០១៧ គឺមានការ ចូលរួម និងការពិភាក្សាយ៉ាងផុសផុល ដែលផ្តល់អោយអ្នកចូលរួម មានឱកាសក្នុងការរៀនសូត្រ និងស្វែងយល់អំពីទិន្នន័យ។ យើងយល់ថា នេះជាយន្តការដ៏សំខាន់សម្រាប់អ្នកពាក់ព័ន្ធក្នុងការ ចាប់ផ្តើមបកស្រាយ ក៏ដូចជាប្រើប្រាស់ទិន្នន័យនេះ និងដើម្បីអោយ ក្រុម LINC និង អង្គការវ៉តធើសេដ បានស្វែងយល់យ៉ាងស៊ីជម្រៅ អំពីន័យគន្លឹះសំខាន់ៗ ដើម្បីធ្វើអោយប្រសើរឡើងនៃការបង្ហាញ។

ទោះជាយ៉ាងណា ទម្រង់នៃការវិភាគបែបនេះ គឺថ្មីសម្រាប់អ្នក ពាក់ព័ន្ធជាច្រើន បើផ្អែកលើហេតុផលមួយចំនួន។ ទី១ គំនិតថ្មី ត្រូវបានធ្វើការណែនាំ ដោយប្រមូលទិន្នន័យ នៃការវិភាគបណ្តាញ បែបជំរឿន និងរូបភាពនៃទិន្នន័យបែបទំនាក់ទំនង ធ្វើការចងក្រង នូវកត្តានៃការវិភាគក្នុងចំលើយបើក។ ទី២ នៅក្នុងប្រទេសកម្ពុជា វាជារឿងធ្វើទូទៅដែលយើងមានអង្គប្រជុំតុមូល ដើម្បីចែករំលែក លទ្ធផល តែការធ្វើបទបង្ហាញជាជាងធ្វើសិក្ខាសាលាបែបលក្ខណៈ ពិគ្រោះយោបល់ ដែលទទួលបានមតិយោបល់ពីអ្នកពាក់ព័ន្ធ មិនមែនជារឿងធ្វើទូទៅនោះទេ។ លើសពីនេះទៀត អ្នកពាក់ព័ន្ធ ដែលនៅថ្នាក់ជាតិពុំធ្លាប់នឹងការត្រួតពិនិត្យឡើងវិញនូវទិន្នន័យ នៃវិស័យអនាម័យជនបទអំពីខ្លួនឯង តែធ្លាប់តែមើលទៅលើក្រុម គ្រួសារជនបទ។ នៅក្នុងលក្ខខណ្ឌទាំងនេះ គឺតម្រូវអោយអ្នក ពាក់ព័ន្ធ ចំណាយពេលវេលាបន្ថែម ដើម្បីទទួលយកទិន្នន័យ និងស្វែងយល់អំពីផលប៉ះពាល់ ដើម្បីបន្តរំពឹងគិតអំពីលទ្ធផល ជំហានបន្ទាប់។

### បណ្តាញអនាម័យជនបទ បានចាប់ផ្តើមធ្វើការទៅលើកការរកឃើញ មួយចំនួនហើយ

ការរកឃើញ និងសកម្មភាពច្បាស់លាស់ ពីការវិភាគបានបង្ហាញថា ការខិតខំប្រឹងប្រែង ពីអ្នកពាក់ព័ន្ធបានចាប់ផ្តើមតាំងពីមុនការសិក្សា នេះមកម្ល៉េះ។ បើទោះជាមានការតម្រូវអោយអ្នកពាក់ព័ន្ធ ចំណាយ ពេលវេលាដើម្បីស្វែងយល់អំពីទិន្នន័យ សមាជិកនៃបណ្តាញមួយ ចំនួន បានចាប់ផ្តើមដំណើរការឆ្លើយតបទៅនឹងការរកឃើញមួយចំនួន ហើយ។ ឧទាហរណ៍ជាក់ស្តែងមួយ គឺអនុក្រុមស្ត្រី នៅក្នុងបណ្តាញទឹក និងអនាម័យជនបទ ដែលបានបង្កើតឡើង ដើម្បីប្រមូលចំណាប់ អារម្មណ៍របស់ស្ត្រីអោយចូលរួមក្នុងអនុក្រុមបណ្តាញទឹកនិងអនាម័យ ជនបទនេះ។ ចំណាប់អារម្មណ៍នេះ មានតាំងពីមុនការសិក្សាមកម្ល៉េះ ប៉ុន្តែការរក ឃើញ នៃការទំនាក់ទំនងទាប របស់អង្គការ ដែលស្ត្រីជាអ្នក គ្រប់គ្រង បានពន្លឿនចលនានេះអោយកាន់កើនឡើង។ ឧទាហរណ៍ ទី២ ភាពមិនស្របគ្នា នៅក្នុងការប្រើប្រាស់ភាសាបានជំរុញអោយ ក្រសួងអភិវឌ្ឍន៍ជនបទ ធ្វើការប្រជុំក្រុមអនុវិស័យអនាម័យជនបទ (RuSH Subgroub) កាលពីខែ ធ្នូ ឆ្នាំ២០១៧ ជាភាសាខ្មែរ ដោយមាន ការបកប្រែជាភាសាអង់គ្លេសជាលើកទីមួយ។

### ការវិភាគ បានផ្តល់ជាការណែនាំ សំរាប់ជំហ៊ានបន្ទាប់ ក្នុងការពន្លឿនការ អភិវឌ្ឍន៍នៃបណ្តាញ

ជាញឹកញាប់ វាមានការលំបាកក្នុងការស្វែងយល់ថា គួរធ្វើយ៉ាងដូច ម្តេច និងនៅចំនុចណា ដើម្បីធ្វើអន្តរាគមន៍មួយ អោយមានផលដ៏ល្អ ប្រសើរ នៅក្នុងប្រព័ន្ធមានភាពស្មុគស្មាញ។ លើសពីការជំរុញ អោយ មានការខិតខំប្រឹងប្រែង នៃក្រុមតូចៗនៃអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតប ទៅនឹងការរកឃើញមួយចំនួន ការសិក្សានេះ ក៏បានផ្តល់អោយមាន ការពិភាក្សាយ៉ាងស៊ីជម្រៅ ក៏ដូចជាសកម្មភាព សំរាប់បណ្តាញវិស័យ អនាម័យជនបទទាំងមូល។ ជាពិសេស វាបានធ្វើអោយមានភាពច្បាស់ នៃតម្រូវការសម្រាប់គាំទ្រ ទៅលើកការពង្រឹងបណ្តាញដើម្បីបង្កើត នូវលក្ខខណ្ឌសំរាប់ការសហការតាមបែបរចនាសម្ព័ន្ធក្នុងនៅក្នុងវិស័យ នេះ។ ដោយមានក្រសួងអភិវឌ្ឍន៍ជនបទ ជាចំនុចកណ្តាល និងមាន ទំនាក់ទំនងយ៉ាងខ្លាំង អ្នកទាំងនោះដើរតួយ៉ាងសំខាន់ ក្នុងការគាំទ្រ ក៏ដូចជាទទួលបានផលប្រយោជន៍ ពីការពង្រឹងបណ្តាញនេះផងដែរ។ ជំហ៊ានបន្ទាប់ដែលបានគ្រោងទុករួមមានដូចជាវគ្គកំណត់ចក្ខុវិស័យ សំរាប់បណ្តាញអនាម័យជនបទ ជុំវិញការផ្លាស់ប្តូរផ្សេងៗ ដែល ទាំងអស់គ្នាចង់ឃើញនៅក្នុងប្រព័ន្ធ និងរចនាសម្ព័ន្ធបណ្តាញ។

## សេចក្តីថ្លែងអំណរគុណ

សេចក្តីសង្ខេប នៃការស្រាវជ្រាវនេះបានរៀបចំដោយ Rich Fromer និង Megan McDermott ជាមួយការរួមចំណែកមិនអាចកាត់ថ្លៃបាន និងការ គាំទ្រពីក្រុមការងារនិរន្តភាពនៃទឹក Liz Jordan និង Amy Javernick-Will។
សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង Rich (rfromer@linclocal.org) ឬ Janita Bartell (janita@watershedasia.org)

អំពីដៃគូសិក្សា អំពីនិរន្តភាពនៃប្រព័ន្ធទឹក SWS កំពុងធ្វើការកំណត់ និងសាកល្បងដំណោះ ស្រាយការដឹកនាំបែបមូលដ្ឋាន ចំពោះបញ្ហាប្រឈម នៃការអភិវឌ្ឍប្រព័ន្ធក្នុងស្រុក ដែលផ្តល់អោយនិរន្តភាពការផ្តល់សេវាទឹក និងអនាម័យ។ សេចក្តីសង្ខេបនេះអាច ធ្វើទៅបាន ដោយមានការគាំទ្រ ពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារ សម្រាប់ការអភិវឌ្ឍន៍អន្តជាតិ (USAID) ក្រោមកិច្ចសហប្រតិបត្តិការ AIDOAA-A-16-00075។ ចំពោះមាតិកា គឺជាការទទួលខុសត្រូវ នៃគូសិក្សាអំពីនិរន្តភាពនៃប្រព័ន្ធទឹក ដែលមិនមែនសំដៅទៅលើការ ឆ្លុះបញ្ចាំងរបស់ USAID ឬ រដ្ឋភិបាលរបស់សហរដ្ឋអាមេរិច ឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.globalwater.org/SWS, ឬ ទំនាក់ទំនង Ella Lazarte (Mlazate@usaid.gov) ឬ Eddy Perez (Eddy.Perez@colorado.edu)